គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

លេខ: 65 សណ.គក

ព្រះរាជាណាចក្រកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រិត និង វឌ្ឍនភាពសង្គម

ភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០

# សេចក្តីកំណត់
## ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សខេត្ត—ក្រុង

*********

- យោងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស
- អនុវត្តសេចក្តីសំរេចចិត្តសន្និបាតគណៈកម្មាធិការកណ្តាលលើកទី ២៦ អំពីការងារចាត់តាំងកសាងគណបក្ស
- ផ្អែកតាមសំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្សនាដំណាក់កាលបច្ចុប្បន្ន
- យោងស្មារតីអង្គប្រជុំគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ៣០ .៥.២០០០

### គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល

កំណត់អំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដូចខាងក្រោម :

### I — <u>តួនាទី ភារកិច្ច សិទ្ធិ</u>

**ក- <u>អំពីតួនាទី</u> :**

គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ជាស្ថាប័នដឹកនាំរបស់គណបក្ស នៅចន្លោះពីមហាសន្និបាតគណបក្សខេត្ត-ក្រុងមួយទៅមហាសន្និបាតមួយទៀត ដែលមានភារៈទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការកណ្តាលនិងគណបក្សថ្នាក់ខ្លួន ក្នុងការដឹកនាំនិងត្រួតពិនិត្យគ្រប់វិស័យការងាររបស់គណបក្ស ដើម្បីអនុវត្តរាល់ភារកិច្ចនយោបាយ ដែលគណបក្សថ្នាក់លើបានកំណត់ និងសេចក្តីសំរេចចិត្តរបស់មហាសន្និបាតថ្នាក់ខ្លួនអោយបានសំរេច រួមចំណែកយ៉ាងសកម្មក្នុងបុព្វហេតុការពារ និងកសាងប្រទេសជាតិ ។

**ខ- <u>អំពីភារកិច្ច</u> :**

ភារកិច្ចសំខាន់ៗ របស់គណៈកម្មាធិការគណបក្សខេត្ត-ក្រុង រួមមាន :

១ - ក្តាប់ជាប់លក្ខន្តិក: មាគ៌ា កម្មវិធីនយោបាយរបស់គណបក្ស គោលការណ៍ សេចក្តីសំរេចចិត្តនានារបស់គណ:កម្មាធិការកណ្តាល និងសេចក្តីសំរេចចិត្តនៃមហាសន្និបាតគណបក្សខេត្ត-ក្រុង និងក្តាប់ជាប់លក្ខណ:ពិសេសសភាពការណ៍ជាក់ស្តែងគ្រប់វិស័យរបស់ខេត្ត-ក្រុង ហើយកំណត់ទិសដៅ ភារកិច្ច គោលការណ៍ និងវិធានការអនុវត្តអោយបានសមស្រប ព្រមទាំងដឹកនាំគណបក្សថ្នាក់ស្រុក-ខណ្ឌ និងរាល់អង្គការចាត់តាំងគណបក្សចំណុះ អោយអនុវត្តបានសំរេចជោគជ័យ ។

២ - ដឹកនាំការងារកសាងពង្រឹងគណបក្ស ពីថ្នាក់ខេត្ត-ក្រុង រហូតដល់មូលដ្ឋាន អំពីវិស័យនយោបាយ សតិអារម្មណ៍ ចាត់តាំង ត្រួតពិនិត្យ ហិរញ្ញវត្ថុ និងការងារបណ្តុះបណ្តាល រៀបចំ និងគ្រប់គ្រងមន្ត្រីដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ។

៣ - ដឹកនាំការងារកសាងពង្រឹងអង្គការចាត់តាំងមូលដ្ឋានគណបក្ស ការងារគ្រប់គ្រង និងកសាងពង្រីកសមាជិកគណបក្ស និងការងារចលនាមហាជន សំដៅពង្រឹងរាល់សកម្មភាពរបស់គណបក្ស និងប្រមូលផ្តុំបាននូវកំលាំងគាំទ្រដ៏ទូលំទូលាយអនុវត្តកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស ។

៤ - ណែនាំគ្រើនរំលឹកមន្ត្រីគណបក្សដែលត្រូវបានប្រគល់ភារកិច្ចអោយទទួលបន្ទុកការងារនៅគ្រប់ស្ថាប័នមន្ទីរជុំវិញខេត្ត-ក្រុង ព្រមទាំងអង្គភាពផ្សេងៗដែលស្ថិតក្នុងភូមិសាស្ត្រខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តការងារគណបក្ស ខិតខំជំរុញការអនុវត្តន៍ភារកិច្ចរក្សាស្ថិរភាពសន្តិសុខ សណ្តាប់ធ្នាប់សាធារណ: ភារកិច្ចសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

៥ - ថែរក្សា និងពង្រីកសមិទ្ធផលរបស់គណបក្សនៅគ្រប់មូលដ្ឋាន យកចិត្តទុកដាក់គិតគូរកែលំអលើកស្ទួយជីវភាពរបស់ប្រជាជន ។

**គ— <u>អំពីសិទ្ធិ</u> :**

គណ:កម្មាធិការគណបក្សខេត្ត-ក្រុងមានសិទ្ធិ :

១ - ណែនាំ និងត្រួតពិនិត្យការអនុវត្តន៍រាល់ភារកិច្ចការងាររបស់គណបក្សក្នុងក្របខ័ណ្ឌមូលដ្ឋាន ខេត្ត-ក្រុងរបស់ខ្លួន ។

២ - សំរេចតែងតាំង តម្លើងឋាន: ប្រគល់ភារកិច្ច លើកសសើរ និងដាក់វិន័យចំពោះមន្ត្រីគណបក្ស ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ ។

៣ - សំរេចការរៀបចំមន្ត្រីស្នាក់ការគណបក្សខេត្ត-ក្រុង បណ្តាគណ: និងផ្នែកចំណុះផ្ទាល់ ចាប់ពីថ្នាក់អនុប្រធានគណ: និងអនុប្រធានមន្ទីរគណបក្សខេត្ត-ក្រុងចុះ ។

៤ - សំរេចការរៀបចំប្រធានបណ្តាគណ: និងផ្នែកចំណុះផ្ទាល់គណ:កម្មាធិការគណបក្សស្រុក-ខណ្ឌ ។

៥ - សំរេចការរៀបចំបណ្តោះអាសន្នសមាសភាពគណៈកម្មាធិការគណបក្សស្រុក-ខណ្ឌ ចាប់ពីថ្នាក់អនុប្រធានចុះ ។

៦ - សំរេចបង្កើត រំសាយ និងរៀបចំបណ្តោះអាសន្នសមាសភាពដឹកនាំគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះ សាខាចំណុះផ្ទាល់ និងសាខាពិសេស ។

៧ - ចូលរួមយោបល់អំពីការរៀបចំមន្ត្រីគណបក្ស ចូលកាន់មុខនាទីក្នុងបណ្តាស្ថាប័នមន្ទីរជុំវិញខេត្ត-ក្រុង។

៨ - លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលដើម្បីសុំសេចក្តីសំរេច អំពីការងារមន្ត្រីគណបក្សក្នុងក្របខ័ណ្ឌខេត្ត-ក្រុង ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់កណ្តាល និងអំពីការងារគណបក្ស ដែលមានការលំបាកស្មុគ្រស្មាញ និងសំណូមពររបស់សមាជិកគណបក្ស និងមហាជនប្រជាជននៅមូលដ្ឋាន ដែលគណៈកម្មាធិការគណបក្សខេត្ត-ក្រុងមិនអាចដោះស្រាយបាន ។

## II—រចនាសម្ព័ន្ធ អង្គការចាត់តាំង :

### ក-អំពីរចនាសម្ព័ន្ធ

រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ត្រូវមានមន្ត្រីវ័យចាស់ វ័យក្មេង ជានារីភេទ ជាជនជាតិភាគតិច ( នៅមូលដ្ឋានដែលមានជនជាតិភាគតិចច្រើន ) ហើយជាមន្ត្រីគណបក្សដែលមានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈ គោលជំហរនយោបាយរឹងមាំ មានគុណធម៌ សីលធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន ប្រជាជន មានសមត្ថភាពរួមចំណែកក្នុងការដឹកនាំរួមរបស់គណៈកម្មាធិការគណបក្ស និងមានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

គណៈកម្មាធិការគណបក្សខេត្ត-ក្រុងត្រូវមានប្រធាន ១ រូប អនុប្រធាន ២ រូប សមាជិកអចិន្ត្រៃយ៍ និងសមាជិកមួយចំនួនតាមការកំណត់ ។

ការរៀបចំសមាសភាពនៃគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

- គណៈកម្មាធិការគណបក្សខេត្ត-ក្រុង រួមមានសមាសភាពមន្ត្រីគណបក្សជាអភិបាល អភិបាលរងខេត្ត-ក្រុង តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាដែលចាំបាច់ មន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំ និងមានឥទ្ធិពលល្អ ប្រធានគណៈត្រួតពិនិត្យ ប្រធានគណៈចាត់តាំង ប្រធានគណៈឃោសនាអប់រំ ប្រធានគណៈហិរញ្ញវត្ថុ ប្រធានមន្ទីរគណបក្សខេត្ត-ក្រុង មន្ត្រីដឹកនាំនៅតាមមន្ទីរ អង្គភាពសំខាន់ៗ ជាអាទិ៍ : កងកំលាំងប្រដាប់អាវុធ អប់រំ ខុទ្ទកាល័យសាលាខេត្ត កសិកម្ម សុខាភិបាល សាធារណៈការ សេដ្ឋកិច្ចហិរញ្ញវត្ថុ ពត៌មាន សង្គមកិច្ច កិច្ចការនារី និងបណ្តាប្រធានគណៈកម្មាធិការគណបក្សស្រុក-ខណ្ឌ ។ ក្នុងករណីប្រធានគណៈ ឬប្រធានមន្ទីរគណបក្សខេត្ត-ក្រុងជាសមាជិកគណៈអចិន្ត្រៃយ៍ ទទួលបន្ទុកបន្ថែមផ្នែកការងារផ្សេងទៀត អនុប្រធានគណៈនោះ ឬអនុប្រធានមន្ទីរគណបក្សអាចជាសមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ។

- គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង រួមមានសមាសភាពមន្ត្រីគណបក្ស ជាអភិបាល អភិបាលរងខេត្ត-ក្រុង តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាដែលចាំបាច់ មន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំនិងមានឥទ្ធិពលល្អ ប្រធានគណៈត្រួតពិនិត្យ ប្រធានគណៈចាត់តាំង ប្រធានគណៈឃោសនាអប់រំ ប្រធានគណៈហិរញ្ញវត្ថុ ប្រធានមន្ទីរគណបក្សខេត្ត-ក្រុង មន្ត្រីដឹកនាំនៅក្នុងកងកំលាំងប្រដាប់អាវុធ និងបណ្តាមន្ទីរសំខាន់ៗ ជាអាទិ៍ : អប់រំ ឧទ្ទកាលយ៍សាលាខេត្ត កសិកម្ម សេដ្ឋកិច្ចហិរញ្ញវត្ថុ កិច្ចការនារី ។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការគណបក្សស្រុក-ខណ្ឌដែលជាទីប្រជុំជននៃទីតាំងរដ្ឋបាលខេត្ត-ក្រុង អាចជាសមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ។

- ផ្អែកលើសំណូមពរនៃការងារដឹកនាំរបស់គណបក្សខេត្ត-ក្រុងនាពេលបច្ចុប្បន្ន គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ត្រូវបង្កើតគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស រួមមានអនុប្រធានប្រចាំការគណៈកម្មាធិការគណបក្សខេត្ត-ក្រុងជាប្រធាន និងមានសមាជិកមួយចំនួនតាមការកំណត់ ដែលត្រូវជ្រើសរើសយកពីសមាសភាពជាប្រធានគណៈត្រួតពិនិត្យ ប្រធានគណៈចាត់តាំង ប្រធានគណៈឃោសនាអប់រំ ប្រធានគណៈហិរញ្ញវត្ថុ ប្រធានមន្ទីរគណបក្សខេត្ត-ក្រុង ។

**៩- អំពីបរិមាណសមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង :**

១ - ការបែងចែកប្រភេទខេត្ត-ក្រុង :

ដោយផ្អែកទៅលើបរិមាណសមាជិកគណបក្សនៅមូលដ្ឋាន និងភូមិសាស្ត្រខេត្ត-ក្រុងដែលមានចំនួនស្រុក-ខណ្ឌតិច ឬច្រើន បណ្តាខេត្ត-ក្រុងទូទាំងប្រទេសត្រូវបានបែងចែកជា ៣ ប្រភេទដូចខាងក្រោម :

- ប្រភេទទី ១ ខេត្ត-ក្រុងធំរួមមាន : ក្រុងភ្នំពេញ ខេត្តកំពង់ចាម ព្រៃវែង កណ្តាល តាកែវ សៀមរាប កំពង់ស្ពឺ ស្វាយរៀង បាត់ដំបង កំពត កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង ។

- ប្រភេទទី ២ ខេត្តមធ្យមរួមមាន : ខេត្តពោធិសាត់ ក្រចេះ ព្រះវិហារ រតនគិរី ស្ទឹងត្រែង កោះកុង។

- ប្រភេទទី ៣ ខេត្ត-ក្រុងតូចរួមមាន : ខេត្តមណ្ឌលគិរី ឧត្តរមានជ័យ ក្រុងព្រះសីហនុ កែប ប៉ៃលិន ។

២ - បរិមាណសមាជិកគណៈកម្មាធិការគណបក្ស

បរិមាណសមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដែលរួមមានប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិក ត្រូវបានកំណត់ដូចខាងក្រោម :

- សមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង មានចំនួន ៣៥ រូបចុះ ចំពោះខេត្ត-ក្រុងធំ ។
- សមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង មានចំនួន ៣៣ រូបចុះ ចំពោះខេត្តមធ្យម ។

- សមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង មានចំនួន ២៩ រូបចុះ ចំពោះខេត្ត-ក្រុងតូច ។

៣ - <u>បរិមាណសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស</u>

បរិមាណសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដែលរួមមានប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ ត្រូវបានកំណត់អោយមាន មួយភាគបី នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុងទាំងមូល ជាក់ស្តែងគឺ :

- សមាជិកគណៈអចិន្ត្រៃយ៍មានចំនួន ១១ រូបចុះ ចំពោះ ខេត្ត-ក្រុងធំ និងមធ្យម ។

- សមាជិកគណៈអចិន្ត្រៃយ៍មានចំនួន ៩ រូបចុះ ចំពោះខេត្ត-ក្រុងតូច ។

៤ - <u>បរិមាណសមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស</u> :

បរិមាណសមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដែលរួមមាន ប្រធាន និងសមាជិកគណៈប្រចាំការ ត្រូវបានកំណត់ដូចខាងក្រោម ៖

- សមាជិកគណៈប្រចាំការ មានចំនួន ៣ ឬ ៥ រូប ចំពោះខេត្ត-ក្រុងធំ និងមធ្យម ហើយត្រូវតិចជាងពាក់កណ្តាលនៃចំនួនសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សទាំងមូល ។

- សមាជិកគណៈប្រចាំការមានចំនួន ៣ រូបចំពោះខេត្ត-ក្រុងតូច ។

**គ** - គណៈកម្មាធិការគណបក្សខេត្ត-ក្រុងនីមួយៗ ត្រូវផ្អែកលើគោលការណ៍កំណត់ អំពីរចនាសម្ព័ន្ធ លក្ខណសម្បត្តិមន្ត្រី សមាសភាព និងបរិមាណសមាជិកនៃគណៈកម្មាធិការគណបក្ស គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស និងគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដូចខាងលើនេះ និងផ្អែកលើលក្ខណៈពិសេសនៃមូលដ្ឋាន សំណូមពរការងារ និងធនធានមន្ត្រី ដើម្បីលើកសំណើរៀបចំសមាសភាពជាក់ស្តែងអោយបានសមស្រប ។

គណៈកម្មាធិការគណបក្សខេត្ត-ក្រុងនីមួយៗ ត្រូវធ្វើការបែងចែកការងារដល់សមាជិកម្នាក់ៗ ក្នុងគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស អោយទទួលបន្ទុកចង្កោមការងារ ឬផ្នែកការងារនីមួយៗរបស់គណបក្ស និងទទួលបន្ទុកដឹកនាំការងារកសាងពង្រឹងគណបក្ស និងការអនុវត្តន៍នយោបាយរបស់គណបក្សនៅតាមមន្ទីរ អង្គភាព ស្រុក-ខណ្ឌនីមួយៗអោយបានសមស្របតាមសភាពការណ៍ និងសំណូមពរភារកិច្ចជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួនក្នុងដំណាក់កាលនីមួយៗ ។

**ឃ** — ចំពោះសមាជិកគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដែលបានរៀបចំពីមុនមក ហើយមានការផ្លាស់ប្តូរ ឬផ្ទេរភារកិច្ចទៅកាន់មុខដំណែងដែលខុសពីរចនាសម្ព័ន្ធខាងលើ ត្រូវពិនិត្យសំរួលភារកិច្ចអោយស្របតាមសេចក្តីកំណត់នេះ ។

យោងតាមរចនាសម្ព័ន្ធកំណត់ខាងលើនេះ តំណែងប្រធាន អនុប្រធានស្នាក់ការគណបក្សខេត្ត-ក្រុងត្រូវបានបញ្ចប់មិនមានតទៅទៀតទេ ព្រោះគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សទទួលខុសត្រូវដឹកនាំភារកិច្ចការងារនេះជំនួសហើយ ។

**III — របៀបរបបធ្វើការ :**

**ក - គណៈកម្មាធិការគណបក្ស :**

គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដឹកនាំការងាររបស់គណបក្សខេត្ត-ក្រុង ឆ្លងតាមរយៈសន្និបាតពេញអង្គដែលប្រជុំ ១ ខែម្តង ។ បញ្ហាសំខាន់ៗ ត្រូវដាក់ជូនគណៈកម្មាធិការគណបក្សសំរេច រួមមាន ៖

១ - ទិសដៅភារកិច្ចនយោបាយ គោលការណ៍ វិធានការ ចាត់តាំងអនុវត្តសេចក្តីសំរេចចិត្ត និងគោលការណ៍សំខាន់ៗរបស់គណៈកម្មាធិការកណ្តាល និងសេចក្តីសំរេចចិត្តនៃមហាសន្និបាតគណបក្សខេត្ត-ក្រុង។

២ - របាយការណ៍បូកសរុបវាយតំលៃសភាពការណ៍ការងារគណបក្សប្រចាំឆ្នាំ និងទិសដៅ ភារកិច្ច ផែនការប្រចាំឆ្នាំរបស់គណបក្សខេត្ត-ក្រុង ។

៣ - គោលការណ៍ថ្មីសំខាន់ៗ អំពីការងាររបស់គណបក្ស ។

៤- សំណើរៀបចំសមាសភាពគណៈកម្មាធិការគណបក្សខេត្ត-ក្រុងនិងទីប្រឹក្សាគណៈកម្មាធិការគណបក្ស។

៥ - ការងារមន្ត្រី និងបញ្ហាទាំងឡាយដែលកំណត់ក្នុងលក្ខន្តិកៈគណបក្ស និងកំណត់ដោយគណៈកម្មាធិការកណ្តាល ត្រូវសំរេចដោយគណៈកម្មាធិការគណបក្ស ។

៦ - ខ្លឹមសារត្រៀមរៀបចំបើកមហាសន្និបាតគណបក្សខេត្ត-ក្រុង ។

៧ - បញ្ហាផ្សេងៗដែលសមាជិកភាគច្រើននៃគណៈអចិន្ត្រៃយ៍មិនទាន់មានការឯកភាព និងឃើញថាចាំបាច់ត្រូវលើកយកមកដាក់ជូនគណៈកម្មាធិការគណបក្សពិនិត្យសំរេច ។

**ខ - គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស :**

គណៈអចិន្ត្រៃយ៍ទទួលខុសត្រូវជំនួសមុខគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដឹកនាំការងាររបស់គណបក្សខេត្ត-ក្រុង ក្នុងចន្លោះពេលពីសន្និបាតពេញអង្គមួយទៅសន្និបាតពេញអង្គមួយទៀតរបស់គណៈកម្មាធិការគណបក្ស ។ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុងប្រជុំមួយខែ ២ ដង ក្នុងករណីមានការចាំបាច់បន្ទាន់ អាចប្រជុំមុនពេលកំណត់ ។

ភារកិច្ចការងាររបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង រួមមាន ៖

១ - ណែនាំចាត់តាំងអនុវត្តសេចក្តីសំរេចចិត្តរបស់គណៈកម្មាធិការគណបក្សខេត្ត-ក្រុង និងគោលការណ៍កំណត់ទាំងឡាយរបស់គណៈកម្មាធិការកណ្តាល ។

២ - ដឹកនាំការងាររបស់បណ្តាគណៈ និងមន្ទីរចំណុះគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ។

៣ - ដឹកនាំពង្រឹងខ្សែរយៈអង្គការចាត់តាំងរបស់គណបក្ស និងណែនាំត្រួតពិនិត្យការអនុវត្តន៍រាល់ភារកិច្ច ការងាររបស់គណបក្ស ការងារពង្រឹងមូលដ្ឋាន និងចលនាមហាជន ។

៤ - សំរេចការងារមន្ត្រី ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ និងលើកសំណើរៀបចំមន្ត្រីគណបក្សក្នុង ក្របខ័ណ្ឌខេត្ត-ក្រុង ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់កណ្តាល ។

៥ - អនុវត្តរបបរាយការណ៍តាមការកំណត់ជូនគណៈកម្មាធិការកណ្តាល និងចាត់តាំងផ្សព្វផ្សាយសភាព ការណ៍ ភារកិច្ចដល់គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ និងសាខាចំណុះ ។

៦ - កោះប្រជុំ និងត្រៀមរៀបចំខ្លឹមសារសន្និបាតគណៈកម្មាធិការគណបក្ស និងរាយការណ៍ជូនគណៈ កម្មាធិការគណបក្ស អំពីសភាពការណ៍ ការងារដែលគណៈអចិន្ត្រៃយ៍បានសំរេច ។

៧ - ទំនាក់ទំនងរាយការណ៍ជូនប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាលចុះជួយខេត្ត-ក្រុង ដើម្បី សុំគោលការណ៍ដឹកនាំណែនាំផ្ទាល់ អំពីការងារគណបក្សចំពោះមូលដ្ឋាន ។

**ខ - <u>គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស</u> :**

គណៈប្រចាំការទទួលខុសត្រូវជំនួសមុខគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដើម្បីដោះ ស្រាយការងារប្រចាំថ្ងៃរបស់គណបក្សខេត្ត-ក្រុង និងអនុវត្តភារកិច្ចដែលគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សបាន ប្រគល់អោយ ។ ប្រធានគណៈប្រចាំការត្រូវធ្វើទំនាក់ទំនងជាប្រចាំជាមួយប្រធាន អនុប្រធានគណៈកម្មាធិការគណបក្ស ដើម្បីរាយការណ៍សុំគោលការណ៍ដឹកនាំ និងត្រួតពិនិត្យ ដោះស្រាយការងារ ។ គណៈប្រចាំការប្រជុំ ១ សប្តាហ៍ម្តង ក្នុងករណីចាំបាច់បន្ទាន់ អាចប្រជុំមុនពេលកំណត់ ។

ភារកិច្ចការងាររបស់គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស រួមមាន ៖

១ - ចាត់ចែងអនុវត្តរាល់គោលការណ៍ សេចក្តីសំរេចរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខេត្ត-ក្រុង ។

២ - កំណត់ទិសដៅ ភារកិច្ចជាក់ស្តែង និងត្រួតពិនិត្យការចាត់តាំងអនុវត្តការងាររបស់បណ្តាគណៈ និង មន្ទីរចំណុះគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ។

៣ - ណែនាំ ត្រួតពិនិត្យការអនុវត្តន៍រាល់ភារកិច្ចការងាររបស់គណបក្សថ្នាក់ក្រោម ។

៤ - សំរេចការតែងតាំង តម្លើងឋានៈ ប្រគល់ភារកិច្ចចំពោះមន្ត្រីគណបក្សខេត្ត-ក្រុង ចាប់ពីថ្នាក់អនុប្រធាន ការិយាល័យចុះ ។

៥ - សំរេចការរៀបចំបណ្តោះអាសន្នសមាសភាពដឹកនាំគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះ សាខា ចំណុះផ្ទាល់ និងសាខាពិសេស ចាប់ពីថ្នាក់អនុប្រធានចុះ ។

**ឃ - <u>ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកនៃគណៈកម្មាធិការគណបក្ស</u> :**

- ប្រធានគណៈកម្មាធិការគណបក្ស ជាប្រធានគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ទទួលខុសត្រូវដឹកនាំរួម តាមគោលការណ៍ដែលបានសំរេចដោយគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ។

- អនុប្រធានទទួលខុសត្រូវជួយប្រធានដឹកនាំការងារមួយចំនួនតាមការប្រគល់ភារកិច្ចរបស់ប្រធាននិងគណៈអចិន្ត្រៃយ៍ និងតំណាងអោយប្រធាននៅពេលដែលប្រធានអវត្តមាន ។ អនុប្រធាន ១ រូបត្រូវបានកំណត់ភារកិច្ចជាអនុប្រធានប្រចាំការ និងជាប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ។

- សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ត្រូវក្តាប់ជាប់នូវសេចក្តីសំរេចចិត្ត និងគោលការណ៍នានារបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ដើម្បីដឹកនាំណែនាំចាត់តាំងអនុវត្តនៅតាមផ្នែកការងារ ឬមូលដ្ឋានដែលខ្លួនទទួលខុសត្រូវ ។ ត្រូវមានរបបចុះជួយដល់មូលដ្ឋាន ចូលរួមចំណែកក្នុងការដឹកនាំការងារគណបក្ស និងការកសាងពង្រឹងគណបក្ស ស្វែងយល់សភាពការណ៍ ក្តាប់សំណូមពររបស់សមាជិកគណបក្ស និងមហាជន ប្រជាជន ដើម្បីលើកសំណើជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ចេញសេចក្តីសំរេចចិត្ត គោលការណ៍ វិធានការដឹកនាំរួម ។

- ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ចូលរួមប្រាស្រ័យក្នុងការដឹកនាំដោយសមូហភាព តាមរយៈអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ ឬគណៈកម្មាធិការគណបក្សខេត្ត-ក្រុង ។ នៅពេលពិភាក្សាការងារ ត្រូវគោរពមតិប្រជាធិបតេយ្យ ក្រោយពេលអនុម័តភាគតិចត្រូវគោរពភាគច្រើន ។ ការអនុម័តរបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស កំណត់យកសម្លេងភាគច្រើននៃសមូហភាពគណៈអចិន្ត្រៃយ៍ទាំងមូល និងគណៈកម្មាធិការគណបក្សទាំងមូល លើកលែងតែការអនុម័តជាកវិន័យដែលមានការកំណត់ដោយឡែក ។

IV — សេចក្តីកំណត់ដែលមានពីមុន ហើយផ្ទុយនឹងសេចក្តីកំណត់នេះ ត្រូវទុកជានិរាករណ៍ ។

គណៈចាត់តាំងគណៈកម្មាធិការកណ្តាល ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សគ្រប់ខេត្ត-ក្រុង មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីកំណត់នេះ ។

**ជ. គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ជា ស៊ីម**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

**លេខ: ១១៣..... សណ.គក**

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩

# សេចក្តីណែនាំ

## ស្តីពីការពង្រីកបន្ថែមរចនាសម្ព័ន្ធ និងបរិមាណ

## សមាជិកគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ

**យោង** :
- សេចក្តីណែនាំបន្ថែមលេខ ១០២ សណ.គក ចុះថ្ងៃទី ២០-០៧-២០០៧ ស្តីពីការរៀបចំរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណកម្មាធិការគណបក្សខេត្ត-ក្រុង
- សេចក្តីណែនាំបន្ថែមលេខ ១០៣ សណ.គក ចុះថ្ងៃទី ៩-០៨-២០០៧ ស្តីពីការរៀបចំរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណកម្មាធិការគណបក្សស្រុក. ខណ្ឌ. ឃុំ. សង្កាត់
- សំណូមពរនៃការងាររបស់គណបក្សនៅក្នុងដំណាក់កាលថ្មី
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍ នៃគណកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណកម្មាធិការកណ្តាល** ណែនាំអំពីការពង្រីកបន្ថែមរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ដូចតទៅ :

១- ទន្ទឹមនឹងបន្តអនុវត្តតាមរចនាសម្ព័ន្ធចាស់ដែលមានរួចហើយ គណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ នីមួយៗ អាចពង្រីករចនាសម្ព័ន្ធរបស់ខ្លួនបន្ថែមទៀត នៅក្នុងជួរ**សមាជិកក្រុមប្រឹក្សារាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ** ដែលជាសមាជិកគណបក្សយើង និងជាអ្នកដែលមានលក្ខណៈសម្បត្តិសមស្របគ្រប់គ្រាន់ ។

២- ផ្អែកលើនេះ បរិមាណសមាជិកគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក ខណ្ឌ អាចកើនឡើងតាមជាក់ស្តែង ។ រីឯបរិមាណសមាជិកគណៈអចិន្ត្រៃយ៍នៃគណកម្មាធិការគណបក្សរាជធានី. ខេត្ត ក្រុង. ស្រុក. ខណ្ឌ ក៏អាចកើនឡើងដែរ តែកំណត់មិនអោយលើស ១/៣ នៃចំនួនសមាជិកគណកម្មាធិការគណបក្សរាជធានី ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ឡើយ ។

៣- ចំពោះសមាជិកក្រុមប្រឹក្សារាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ដែលកំពុងមានឋានៈនាទីនៅក្នុងគណកម្មាធិការគណបក្ស ឬក្នុងគណៈអចិន្ត្រៃយ៍នៃគណកម្មាធិការគណបក្សរាជធានី. ខេត្ត ក្រុង. ស្រុក ខណ្ឌ រួចហើយនោះ ត្រូវរក្សាទុកនៅដដែល លើកលែងតែមានករណីពិសេសដោយឡែក ។

៤- ចំពោះ**ប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ** ណាមួយដែលពុំមែនជាប្រធាន ឬអនុប្រធានគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ទេនោះ អាចស្នើសុំតែងតាំងជាអនុប្រធានគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ បន្ថែមម្នាក់ទៀតបាន ។

ទទួលបានសេចក្តីណែនាំនេះ ខុទ្ទកាល័យ គណៈចាត់តាំងគណកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ត្រូវអនុវត្តអោយបានល្អប្រសើរ ទៅតាមគោលការណ៍ និងនីតិវិធីរបស់គណបក្សយើង ។

ជ.គណៈអចិន្ត្រៃយ៍

ប្រធាន

ជា ស៊ីម

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខៈ១១/១៥ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ,ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ ២០១៥

# សេចក្តីណែនាំស្តីពី
# ការរៀបចំបន្ថែមអភិបាលក្រុង ស្រុក ខណ្ឌ
# ជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត

**__យោង__ :** - សេចក្តីកំណត់លេខៈ៦៥សណ.គក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្ស រាជធានី ខេត្ត

- សេចក្តីណែនាំបន្ថែមលេខៈ ០២/១៥ សណ.គក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការរៀបចំប្រធានគណៈកម្មាធិការគណបក្ស រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សេចក្តីណែនាំបន្ថែមលេខៈ០៦/១៥ សណ.គក ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០១៥ ស្តីពីការអនុវត្តគោលការណ៍រៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សំណូមពរនៃការងារគណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំរបស់គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីការរៀបចំបន្ថែមអភិបាលក្រុង ស្រុក ខណ្ឌជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដូចខាងក្រោមៈ

ទន្ទឹមនឹងបន្តអនុវត្តគោលការណ៍រៀបចំរចនាសម្ព័ន្ធដែលមានរួចហើយ ចំពោះក្រុង ស្រុក ខណ្ឌ ដែលមានប្រធានក្រុមប្រឹក្សាជាប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ និងជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្តរួចហើយ ត្រូវរៀបចំបន្ថែម អភិបាលក្រុង ស្រុក ខណ្ឌ ជាអនុ

ប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ និងជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ០១រូបទៀត។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានភារកិច្ចចាត់តាំងអនុវត្តតាមសេចក្តីណែនាំនេះ ។

ជ.គណៈអចិន្ត្រៃយ៍

ប្រធាន

ហ៊ុន សែន

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ: ០១/១៦ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៦

# សេចក្តីណែនាំបន្ថែម
# ស្តីពី
# ការរៀបចំប្រធានគណៈចលនាមហាជន និងប្រធានគណៈចលនាយុវជននៃគណបក្សរាជធានី ខេត្ត

**យោង:** -សេចក្តីសម្រេចលេខ ៣២៧/១៥ សស.គក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥។
-ស្មារតីនៃសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៣៩ អាណត្តិទីV ។
-ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦។

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំបន្ថែមអំពីការរៀបចំប្រធានគណៈចលនាមហាជន និងប្រធានគណៈចលនាយុវជនគណបក្សរាជធានី ខេត្ត ដូចខាងក្រោម៖

ដើម្បីបន្តជំរុញការងារចលនាមហាជន ជាពិសេសការងារចលនាយុវជនឲ្យកាន់តែមានប្រសិទ្ធភាព គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវរៀបចំមន្ត្រីគណបក្ស ដែលជាអភិបាលរាជធានី ខេត្ត ឲ្យទទួលបន្ទុកជាប្រធានគណៈចលនាមហាជន និងជាប្រធានគណៈចលនាយុវជននៃគណបក្សរាជធានី ខេត្ត។

ចំពោះថ្នាក់ក្រុង ស្រុក ខណ្ឌ ក៏ត្រូវរៀបចំមន្ត្រីគណបក្ស ដែលជាអភិបាលក្រុង ស្រុក ខណ្ឌ ឲ្យទទួលបន្ទុកផ្ទាល់ការងារចលនាមហាជន និងការងារចលនាយុវជនផងដែរ។

សេចក្តីសម្រេចពីមុន ដែលមានខ្លឹមសារផ្ទុយពីសេចក្តីណែនាំបន្ថែមនេះ ចាត់ទុកជានិរាករណ៍។

ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំបន្ថែមនេះ។

**ជ.គណៈអចិន្ត្រៃយ៍**
**ប្រធាន**

**ហ៊ុន សែន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខៈ 05/16 សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ,ថ្ងៃទី 12 ខែឧសភា ឆ្នាំ២០១៦

# សេចក្តីណែនាំបន្ថែម
# ស្តីពី
# បរិមាណ និងសមាសភាពគណៈប្រចាំការនៃ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត

**យោង** - សេចក្តីកំណត់លេខៈ ៦៥ សណ.គក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០
- សេចក្តីណែនាំបន្ថែមលេខៈ ១០២ សណ.គក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧
- សេចក្តីណែនាំលេខៈ ១១៣ សណ.គក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩
- សំណូមពរនៃការងារគណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៦

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំបន្ថែមអំពីបរិមាណ និងការរៀបចំសមាសភាពគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដូចតទៅ ៖

១- បរិមាណសមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវបានកំណត់ឲ្យមានចំនួន ៥ ឬ ៧រូប ហើយត្រូវតិចជាងពាក់កណ្តាលនៃចំនួនសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សទាំងមូល ។

២- សមាសភាពគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវមានអនុប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ១រូប ជាប្រធាន និងសមាជិកមួយចំនួនតាមការកំណត់ ដែលរួមមានបណ្តាប្រធានគណៈជំនាញ និងប្រធានមន្ទីរគណបក្សរាជធានី ខេត្ត ។ ចំពោះករណីដែលប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ទទួលបន្ទុកផ្ទាល់ជាប្រធានគណៈជំនាញណាមួយ អាចរៀបចំអនុប្រធាន ១រូប នៃគណៈជំនាញនោះជាសមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធនិង គណៈកម្មាធិការគណបក្សរាជធានី ខេត្ត មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំបន្ថែមនេះឲ្យមានប្រសិទ្ធភាព ។

ជ.គណៈអចិន្ត្រៃយ៍

ប្រធាន

ហ៊ុន សែន

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល
លេខៈ ០០៣/១៨ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃ ១២ កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ពស ២៥៦១
ភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៨

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំបន្ថែម ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត

**យោង:**
- សេចក្តីកំណត់លេខ ៦៥ សណ.គក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត
- សេចក្តីណែនាំលេខ ០២/១៥ សណ.គក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការរៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សេចក្តីណែនាំបន្ថែមលេខ ០៦/១៥ សណ.គក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៥ ស្តីពីការអនុវត្តគោលការណ៍រៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សំណូមពរនៃការងារគណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីការរៀបចំបន្ថែមប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដូចខាងក្រោមៈ

ទន្ទឹមនឹងបន្តអនុវត្តគោលការណ៍រៀបចំរចនាសម្ព័ន្ធដែលមានរួចហើយ ចំពោះក្រុង ស្រុក ខណ្ឌ ដែលមានអភិបាលជាប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ និងជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្តរួចហើយ ត្រូវពិនិត្យរៀបចំប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ១រូបទៀត ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចចាត់តាំងអនុវត្តតាមសេចក្តីណែនាំនេះ ។

ជ.គណៈអចិន្ត្រៃយ៍
ប្រធាន

ហ៊ុន សែន

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខៈ០០៤/០៧២៥/សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃពុធ ១៤កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០២៥

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំអនុប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**យោង** -សេចក្តីកំណត់លេខ ៦៥ សណ.គក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០០ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សខេត្ត ក្រុង

-សេចក្តីកំណត់លេខ ៧៧ សណ.គក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សស្រុក ខណ្ឌ

-សំណូមពរ និងភារកិច្ចរបស់គណបក្សនាដំណាក់កាលបច្ចុប្បន្ន

-ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១ខែកក្កដា ឆ្នាំ២០២៥

-មតិរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំបន្ថែមអំពីការរៀបចំអនុប្រធានគណៈកម្មាធិការគណបក្សរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

១-អនុប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ជារួមត្រូវមានចំនួន ១ ទៅ ២រូប ។

២-ចំពោះរាជធានីភ្នំពេញ និងបណ្តាខេត្តកំពង់ចាម ព្រៃវែង កណ្តាល តាកែវ សៀមរាប កំពង់ស្ពឺ ស្វាយរៀង បាត់ដំបង កំពត កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង និងត្បូងឃ្មុំ អាចរៀបចំឱ្យមានអនុប្រធានគណៈកម្មាធិការគណបក្សចំនួន ៣រូប ។

៣-ចំពោះក្រុង ស្រុក ខណ្ឌ ដែលមានបរិមាណសមាជិកគណបក្សច្រើន និងមានអង្គការ

ចាត់តាំងគណបក្សចំណុះផ្ទាល់ចំនួន ១២ឡើងទៅ អាចរៀបចំឱ្យមានអនុប្រធានគណៈកម្មាធិការគណបក្សចំនួន ៣រូប ។

ខុទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ គណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ។

ជ.គណៈអចិន្ត្រៃយ៍
ប្រធាន

ហ៊ុន សែន